ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា

# ញត្តិគាំទ្រ

តាងនាមថ្នាក់ដឹកនាំនិងនាយទាហាន នាយទាហានរងទាំងអស់ នៅក្នុងអគ្គនាយកដ្ឋានយោធសេវា នៃក្រសួងការពារជាតិ សូមប្រកាសជាឱឡារិកនិងគាំទ្រពេញទំហឹង ចំពោះសារនយោបាយពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងនាវសៀល ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ដោយបានបញ្ជាក់យ៉ាងច្បាស់ពីការចូលកាន់ដំណែងរបស់ ឯកឧត្តម បណ្ឌិត **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ ចាប់ពីល្ងាចថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ដ៏ខ្លីខាងមុខនេះ ។

ឯកឧត្តម បណ្ឌិត **ហ៊ុន ម៉ាណែត** គឺជាឥស្សរជនដ៏ឆ្នើមវ័យក្មេង មានចំណេះដឹងខ្ពស់ពោរពេញដោយសមត្ថភាព និងទេពកុសលខ្ពស់ ព្រមទាំងមានគុណធម៌ សីលធម៌ សុជីវធម៌ល្អ ដោយទទួលបានការកោតសរសើរ គោរពស្រឡាញ់ពីសំណាក់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ ជាពិសេស ក្រៅពីការចូលរួមចំណែកយ៉ាងធំធេងក្នុងការកសាង និងពង្រឹងកងយោធពលខេមរភូមិន្ទ **ឯកឧត្តម បណ្ឌិត** បានដឹកនាំកងទ័ពអាវស រួមជាមួយ លោកជំទាវ **ពេជ ចន្ទមុន្នី** ក្នុងការប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងជោគជ័យ ដោយទទួលបានការកោតសរសើរ និងសាទរពីសំណាក់ប្រជាជនទូទាំងប្រទេស។

យើងខ្ញុំទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម បណ្ឌិត **ហ៊ុន ម៉ាណែត** ពិតជាស័ក្តិសមជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបន្តវេនដឹកនាំ បន្តការពាររបបរាជានិយម ការពារអធិបតេយ្យជាតិ បូរណភាពទឹកដី ការពារសន្តិភាព ស្ថិរភាពនយោបាយ លើកកម្ពស់កិត្យានុភាពជាតិ និងការអភិវឌ្ឍប្រទេសកាន់តែមានភាពរីកចម្រើនលើគ្រប់វិស័យ ដើម្បីវិបុលភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គលរបស់ប្រជាជនកម្ពុជា។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន ក្នុងអគ្គនាយកដ្ឋានយោធសេវា នៃក្រសួងការពារជាតិ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងនូវប្រសាសន៍ដ៏ខ្ពង់ខ្ពស់ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** ដែលជាប្រមុខដឹកនាំដ៏ឈ្លាសវៃ សូមប្តេជ្ញាការពារ និងគាំទ្រយ៉ាងពេញទំហឹង ចំពោះរាជរដ្ឋាភិបាលស្របច្បាប់អាណត្តិទី៧ ដែលកើតចេញពីការបោះឆ្នោត ដោយត្រឹមត្រូវ យុត្តិធម៌ ស្របតាមលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ និងមាន ឯកឧត្តម បណ្ឌិត **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី ដើម្បីបន្តដឹកនាំនាវាកម្ពុជា ឈានឆ្ពោះទៅកាន់វឌ្ឍនភាព ភាពសម្បូររុងរឿង វិបុលភាព និងភាពសុខសាន្តរបស់ប្រជាជន។

ថ្ងៃសុក្រ ១១កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣

Scanned with CamScanner